៣៦០	លោក	សៀង	ណារ៉ុង	គ្រូបង្រៀន	អនុវិទ្យាល័យ ជ្រៃ	ស្រុកថ្មគោល
៣៦១	លោក	ហួន	ពុទ្ធី	គ្រូបង្រៀន	អនុវិទ្យាល័យ ជ្រៃ	ស្រុកថ្មគោល
៣៦២	លោក	ពេជ	សុខ	គ្រូបង្រៀន	អនុវិទ្យាល័យ អូរតាគី	ស្រុកថ្មគោល
៣៦៣	លោក	ហួត	វ៉ាន់នី	គ្រូបង្រៀន	អនុវិទ្យាល័យ អូរតាគី	ស្រុកថ្មគោល
៣៦៤	លោក	សាត	សុភាព	គ្រូបង្រៀន	អនុវិទ្យាល័យ តាម៉ឺន	ស្រុកថ្មគោល
៣៦៥	លោក	ឃួន	សុធារី	គ្រូបង្រៀន	អនុវិទ្យាល័យ តាម៉ឺន	ស្រុកថ្មគោល
៣៦៦	លោកស្រី	ផុន	គិមឡៃ	គ្រូបង្រៀន	បឋមសិក្សា និគម	ស្រុកថ្មគោល
៣៦៧	លោក	អុន	សន	គ្រូបង្រៀន	បឋមសិក្សា គោកឃ្មុំ	ស្រុកថ្មគោល

៣៦៨	លោក	ព្រំ	ម៉ាឡៃ	គ្រូបង្រៀន	បឋមសិក្សា បឹងព្រីង	ស្រុកថ្មគោល
៣៦៩	លោក	ឃួន	សាមេត	គ្រូបង្រៀន	បឋមសិក្សា តាម៉ឺន	ស្រុកថ្មគោល
៣៧០	លោក	មូល	សារេត	នាយក	បឋមសិក្សា ឆ្មា	ស្រុកថ្មគោល
៣៧១	លោក	កើត	សំអឿន	នាយក	បឋមសិក្សា ភូមិទូល	ស្រុកថ្មគោល
៣៧២	លោកស្រី	ង៉ាន	ចាន់ស៊ី	នាយិកា	បឋមសិក្សា ប៉ោយតាសេក	ស្រុកថ្មគោល
៣៧៣	លោកស្រី	សុន	វណ្ណា	នាយិកា	បឋមសិក្សា ស្នួលកោង	ស្រុកថ្មគោល
៣៧៤	លោក	កែវ	សម្បត្តិ	នាយក	បឋមសិក្សា ភូមិជ្រៃ	ស្រុកថ្មគោល
៣៧៥	លោកស្រី	រុន	គុណា	នាយិការង	បឋមសិក្សា គ្រាង	ស្រុកថ្មគោល
៣៧៦	លោក	ជា	វ៉ាន់នី	នាយករង	អនុវិ.បន្ទាយត្រែង	ស្រុកថ្មគោល
៣៧៧	លោក	ជា	ប្រិមប្រិយ៍	នាយករង	អនុ វិទ្យាល័យ អន្លង់រុន	ស្រុកថ្មគោល
៣៧៨	លោក	សំ	វុទ្ធា	នាយករង	អនុវិ.ជ្រោយស្តៅ	ស្រុកថ្មគោល
៣៧៩	លោក	វ៉ាន់	ប៊ុនហោ	គ្រូបង្រៀន	វិទ្យាល័យ ថ្មគោល	ស្រុកថ្មគោល
៣៨០	លោក	ទិត	យ៉ារី	គ្រូបង្រៀន	វិទ្យាល័យ ថ្មគោល	ស្រុកថ្មគោល
៣៨១	លោក	សុខ	សំអឿន	គ្រូបង្រៀន	អនុវិទ្យាល័យ រូងជ្រៃ	ស្រុកថ្មគោល
៣៨២	លោក	សៅ	ស្រួច	គ្រូបង្រៀន	អនុវិទ្យាល័យ និគម	ស្រុកថ្មគោល
៣៨៣	លោក	គិម	វុទ្ធី	គ្រូបង្រៀន	បឋមសិក្សា ប្រគាប	ស្រុកថ្មគោល
៣៨៤	លោក	ទិត	ស៊ីឌី	គ្រូបង្រៀន	បឋមសិក្សា តាសី	ស្រុកថ្មគោល
៣៨៥	លោក	ទេព	គិមហាក់	គ្រូបង្រៀន	បឋមសិក្សា តាសី	ស្រុកថ្មគោល
៣៨៦	លោក	កង	វ៉ាន្នី	គ្រូបង្រៀន	បឋមសិក្សា តាពូង	ស្រុកថ្មគោល
៣៨៧	លោក	មាជ	ដារ៉ា	គ្រូបង្រៀន	បឋមសិក្សា តាពូង	ស្រុកថ្មគោល

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៥. សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតក្រុមការងារអន្តរក្រសួងរៀបចំក្បួនរថយន្តមិត្តភាពអាស៊ាន-ឥណ្ឌា លើកទី២ ឆ្នាំ២០១២ និងក្បួនម៉ូតូធុនធំអាស៊ាន ឆ្នាំ២០១២

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងលិខិតលេខ ២៦៨៦ អស៤.កបទ.សអ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១២ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

សម្រេច

ប្រការ១: ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងរៀបចំក្បួនរថយន្តមិត្តភាព អាស៊ាន-ឥណ្ឌា លើកទី២ឆ្នាំ២០១២ “ASEAN-India Car Rally 2012” ពីថ្ងៃទី០២-០៥ ខែធ្នូ ឆ្នាំ២០១២ និងក្បួនម៉ូតូធុនធំអាស៊ាន ឆ្នាំ២០១២ “ASEAN Bike Fest 2012” ពីថ្ងៃទី០៦-០៨ ខែកក្កដា ឆ្នាំ២០១២ ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ប្រធាន

២-	ឯកឧត្តម	**លឹម ស៊ីដេនីន**	រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន	អនុប្រធាន
៣-	ឯកឧត្តម	**អ៊ុក សុជាតិ**	រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	អនុប្រធាន
៤-	ឯកឧត្តម	**ហោ សារុន**	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធានអចិន្ត្រៃយ៍
៥-	ឯកឧត្តម	**ជា ម៉ូរ៉ា**	អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងទេសចរណ៍	សមាជិក
៦.	ឯកឧត្តម	**ខ៉ាត់ ចំរើន**	ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជា អគ្គលេខាធិការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា	សមាជិក
៧-	ឯកឧត្តម	**គឹម ម៉ូរី**	អគ្គនាយកសាធារណការនៃក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
៨-	ឯកឧត្តម	**ស៊ូ មិសុទ្ធី**	ទីប្រឹក្សារដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជា ប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ	សមាជិក
៩-	ឯកឧត្តម ឧត្តមសេនីយ៍ឯក	**ចាន់ គឹមសេង**	ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ	សមាជិក
១០-	ឯកឧត្តម	**ម៉ី ម៉ារ៉ាឌី**	អគ្គនាយករងអាជ្ញាធរអប្សរា	សមាជិក
១១-	ឯកឧត្តម	**ឡាយ ឫទ្ធី**	អគ្គនាយករងគយនិងរដ្ឋាករកម្ពុជា	សមាជិក
១២-	ឯកឧត្តម	**ផុស សុវណ្ណ**	ទីប្រឹក្សាក្រសួងព័ត៌មាន និងជាអគ្គនាយករង ព័ត៌មាន និងសោតទស្សន៍	សមាជិក
១៣-	លោក	**អ៊ុក សោភ័ណ**	អគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួង ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	សមាជិក
១៤-	ឯកឧត្តម	**ម៉ុន ថាឫទ្ធិ**	អភិបាលរងខេត្តសៀមរាប	សមាជិក
១៥-	ឯកឧត្តម	**អ៊ុត សំអន**	អភិបាលរងខេត្តកំពង់ធំ	សមាជិក
១៦-	ឯកឧត្តម	**សំ ម៉ុនណារិន**	អភិបាលរងខេត្តស្វាយរៀង	សមាជិក
១៧-	លោក	**ទ្រី ណារិន**	អភិបាលរងខេត្តបន្ទាយមានជ័យ	សមាជិក
១៨-	លោក	**កែវ សេន**	អភិបាលរងខេត្តព្រៃវែង	សមាជិក
១៩-	លោក	**រុំ តិត្ថមុនី**	អភិបាលរងខេត្តកំពង់ចាម	សមាជិក
២០-	លោកស្រី	**ទូច សារ៉ុម**	អភិបាលរងរាជធានីភ្នំពេញ	សមាជិក
២១-	លោកស្រី	**សួស សារ៉ាម**	អភិបាលរងខេត្តកណ្តាល	សមាជិក
២២-	លោកស្រី	**ម៊ិន សុគី**	អភិបាលរងខេត្តក្រចេះ	សមាជិក
២៣-	លោក	**ឃុ ប៉ាសិទ្ធិ**	អភិបាលរងខេត្តស្ទឹងត្រែង	សមាជិក
២៤-	លោកស្រី	**ស៊ឹម ម៉ារី**	អភិបាលរងខេត្តបាត់ដំបង	សមាជិក
២៥-	លោក	**កែម សុធឿន**	អភិបាលរងខេត្តពោធិ៍សាត់	សមាជិក
២៦-	លោក	**ឈឹម ឈន**	អភិបាលរងខេត្តកំពង់ឆ្នាំង	សមាជិក
២៧-	លោក	**ផ្លុខ ធឿន**	អគ្គនាយករងនិងជាប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ	សមាជិក

២៨- លោកឧត្តមសេនីយ៍ទោ **ហ៊ឹម យ៉ាន** ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់នៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

២៩- លោក **ប្រាក់ ច័ន្ទនារា** ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ សមាជិក

៣០- លោក **គង់ សុតារក្ស** ប្រធាននាយកដ្ឋានស្ថិតិនិងព័ត៌មានទេសចរណ៍ សមាជិក

៣១- លោកវរសេនីយ៍ឯក **រៀល ពិសិដ្ឋ** នាយការិយាល័យផែនការប្រតិបត្តិការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៣២- លោក **គង់ ណារិទ្ធ** ប្រធានការិយាល័យកិច្ចការអាស៊ាន ក្រសួងសុខាភិបាល សមាជិក

ប្រការ២: ក្រុមការងាររៀបចំក្បួនរថយន្តមិត្តភាពអាស៊ាន-ឥណ្ឌា លើកទី២ និងក្បួនម៉ូតូធុនធំអាស៊ានឆ្នាំ២០១២ មានមុខងារ និងភារកិច្ចដូចតទៅ:

- ពិភាក្សាជាមួយប្រទេសជាដៃគូ ក្នុងការអនុវត្តយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការទេសចរណ៍ ជាពិសេសជាមួយប្រទេសឥណ្ឌា និងបណ្តាប្រទេសជាសមាជិកអាស៊ានដែលមានការពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តផែនការសកម្មភាព និងកម្មវិធីការងារនៃការរៀបចំក្បួនរថយន្តមិត្តភាពអាស៊ាន-ឥណ្ឌាលើកទី២ ពីថ្ងៃទី០២-០៥ ខែធ្នូ ឆ្នាំ២០១២ និងក្បួនម៉ូតូធុនធំអាស៊ាន ពីថ្ងៃទី០៦-០៨ ខែកក្កដា ឆ្នាំ២០១២
- រៀបចំបដិសណ្ឋារកិច្ចស្វាគមន៍ដល់គណៈប្រតិភូ និងក្រុមកីឡាករក្បួនរថយន្តមិត្តភាពអាស៊ាន-ឥណ្ឌា ASEAN- India Car Rally 2012 និងក្បួនម៉ូតូធុនធំអាស៊ាន “ASEAN Bike Fest 2012” នៅតាមបណ្តាខេត្ត រាជធានីដែលឆ្លងកាត់ ជាពិសេសចូលនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែតដោយឆ្លងកាត់តាម ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តកំពង់ចាម ខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តព្រៃវែង និងចេញទៅវិញតាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ខេត្តស្វាយរៀង
- រៀបចំពិធីស្វាគមន៍ពេលមកដល់ (Flag off) នៅច្រកទ្វារប៉ោយប៉ែត និងពិធីជូនដំណើរ (See off) នៅច្រកទ្វារប៉ោយប៉ែតចំពោះក្បួនម៉ូតូ និងច្រកទ្វារបាវិតចំពោះក្បួនរថយន្ត
- រៀបចំការបង្ហាញក្បួនម៉ូតូធុនធំអាស៊ាន ឆ្នាំ២០១២ និងពិធីជប់លៀងជូនគណៈប្រតិភូ ក្រុមកីឡាករ នៅសួនច្បារសម្តេច ហ៊ុន សែន រាជធានីភ្នំពេញ និងថតរូបអនុស្សាវរីយ៍នៅមុខប្រាសាទអង្គរវត្ត
- រៀបចំពិធីជប់លៀងស្វាគមន៍ រាត្រី ASEAN-India Tourism Evening ដល់គណៈប្រតិភូ និងក្រុមកីឡាករនៅខេត្តសៀមរាប
- រៀបចំពិធីជប់លៀងជូនដំណើរដល់គណៈប្រតិភូ និងក្រុមកីឡាកររថយន្តអាស៊ាន-ឥណ្ឌា នៅរាជធានីភ្នំពេញ
- សហការជាមួយស្ថានទូតខ្មែរប្រចាំនៅឥណ្ឌា និងស្ថានទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជាដើម្បីពិភាក្សា និងដោះស្រាយរាល់ការងារដែលពាក់ព័ន្ធ ក្នុងកិច្ចដំណើរការរៀបចំក្បួនរថយន្តមិត្តភាពអាស៊ាន-ឥណ្ឌា លើកទី២ ឆ្នាំ២០១២ ឱ្យមានភាពរលូន
- ត្រូវរៀបចំការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អ ក្នុងអំឡុងពេលក្បួនម៉ូតូធុនធំ និងក្បួនរថយន្តឆ្លងកាត់តាមបណ្តារាជធានី និងខេត្តនានាក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជា
- ត្រូវរៀបចំធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ជាពិសេសតាមវិទ្យុ ទូរទស្សន៍ ដើម្បីឱ្យសាធារណជនបានយល់ដឹងជ្រួតជ្រាប និងចូលរួមក្នុងពិធីនេះ

- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ព្រមទាំងមានសិទ្ធិស្វែងរកទទួលជំនួយ និងការឧបត្ថម្ភនានាដល់កិច្ចដំណើរការនៃពិធីនេះ
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការរៀបចំ និងកិច្ចដំណើរនៃពិធីនេះជូនប្រមុខរាជរដ្ឋាភិបាល។

ប្រការ៣:ក្រុមការងារអន្តរក្រសួងនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅទីស្តីការក្រសួងទេសចរណ៍ និងមានសមាសភាព:

១- ឯកឧត្តម	**ហោ សារុន**	អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍	ប្រធាន
២- លោក	**ផ្លុំ ធឿន**	អគ្គនាយករងនិងជាប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ក្រសួងទេសចរណ៍	អនុប្រធាន
៣-លោក	**សុខ តុងហាប់**	ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក.ទ.ច	សមាជិក
៤- លោកឧត្តមសេនីយ៍ទោ	**ហ៊ឹម យ៉ាន**	ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ	សមាជិក
៥- លោក	**គង់ សុភារក្ស**	ប្រធាននាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ ក.ទ.ច	សមាជិក
៦- លោក	**សំ ឌុទ្ធា**	អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ក.ទ.ច	សមាជិក
៧- លោក	**ទូច ម៉ានី**	អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ក.ទ.ច	សមាជិក
៨- លោក	**ឈុន ណារ៉ាក់**	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន	សមាជិក
៩- លោក	**ឡោ ធូរ៉ា**	អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយ ក.ទ.ច	សមាជិក
១០- លោក	**ជង់ ឡឹម**	ប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ	សមាជិក
១១- លោក	**ង៉ូវ សេងភាក់**	ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប	សមាជិក
១២- លោក	**សេង អាន**	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ធំ	សមាជិក
១៣- លោក	**ស៊ាន សុគុន**	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ចាម	សមាជិក
១៤- លោក	**ង៉ៀង រតនៈ**	ប្រធានមន្ទីរទេសចរណ៍ខេត្តកណ្តាល	សមាជិក
១៥- លោកស្រី	**អេង ណារី**	ប្រធានមន្ទីរទេសចរណ៍ខេត្តព្រៃវែង	សមាជិក
១៦- លោក	**ហ៊ាន់ សារ៉ាត**	ប្រធានមន្ទីរទេសចរណ៍ខេត្តស្វាយរៀង	សមាជិក
១៧- លោក	**រុន តារ៉ា**	ប្រធានមន្ទីរទេសចរណ៍ខេត្តក្រចេះ	សមាជិក
១៨- កញ្ញា	**លួន ធានី**	ប្រធានមន្ទីរទេសចរណ៍ខេត្តស្ទឹងត្រែង	សមាជិក
១៩- លោក	**អ៊ុច អ៊ឺតីនិស្សារ៉ា**	ប្រធានមន្ទីរទេសចរណ៍ខេត្តបាត់ដំបង	សមាជិក
២០- លោក	**ញ៉ូវ សុខ**	ប្រធានមន្ទីរទេសចរណ៍ខេត្តពោធិ៍សាត់	សមាជិក
២១- លោក	**ស៊ីវ រុន**	ប្រធានមន្ទីរទេសចរណ៍ខេត្តកំពង់ឆ្នាំង	សមាជិក
២២- លោក	**ហេង សុខចំរើន**	នាយករងខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងទេសចរណ៍	សមាជិក
២៣- លោក	**ហ៊ា វណ្ណា:**	ជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍	សមាជិក
២៤- លោក	**ស្ងួន ទិមុល**	ជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍	សមាជិក
២៥- លោកស្រី	**គីម សុវណ្ណា**	អនុប្រធានទទួលបន្ទុករួមមន្ទីរទេសចរណ៍រាជធានីភ្នំពេញ	សមាជិក
២៦- លោកវរសេនីយ៍ឯក	**រៀល ពិសិដ្ឋ**	នាយការិយាល័យផែនការប្រតិបត្តិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក

២៧- លោក **គង់ ណារិទ្ធ** ប្រធានការិយាល័យកិច្ចការអាស៊ាន ក្រសួងសុខាភិបាល សមាជិក

២៨- លោក **ចៅ វណ្ណារិទ្ធ** នាយរងការិយាល័យនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ សមាជិក

២៩- លោក **ចឹក តារុណា** មន្ត្រីនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ សមាជិក

៣០- លោក **ហោ សុគន្ធ** មន្ត្រីនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ សមាជិក

ប្រការ៤:

- ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិការបស់ក្រសួងទេសចរណ៍ក្នុងការបំពេញការងារ។
- សមាជិកនៃក្រុមការងារអន្តរក្រសួងនេះត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

ប្រការ៥: ក្រុមការងារអន្តរក្រសួងនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

ប្រការ៦: បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៧: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងអភិបាលរាជធានី ខេត្តពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ ៧
-ឯកសារ- កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤០៤ ឧ.ស.ក.ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភាឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៧៨៧/១២ គ.វ.ក ចុះថ្ងៃទី០៦.០៤.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យៅ ធីង ស៊ូ មេធៀរៀល ចុះថ្ងៃទី២៦.០៣.២០១២

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន យៅ ធីង ស៊ូ មេធៀរៀល (YAO TING SHOES MATERIALS CO.,LTD. តំណាងដោយ លោក YANG, YUNG-TAI សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 303736864 ចុះថ្ងៃទី២៩.១១.២០១១ អាសយដ្ឋានបច្ចុប្បន្ន ៖ No.27, Hudongli, Daxi San Street, Xuhou Quarter, Changhua District, Taiwan. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាផលិតកម្ម ៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
គ្រឿងបន្សំស្បែកជើង	១៥២០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

ផ្លាកឈ្មោះរោងចក្រ៖ *"រោងចក្រ ផលិតគ្រឿងបន្ទរស្បែកជើង យៅ ធីង ស៊ីមេធៀរៀល "*

ទីតាំងរោងចក្រ៖ *" ឡូត៍លេខ៧៦៥ ភូមិកន្ទោកជើង សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចដូល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បី អនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ: ៥០៧ ឧ.ស.ម.ក.ឧ / ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១៤

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការ ប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ៣០១១/១១ គ.វ.ក ចុះថ្ងៃទី២៦.១២.២០១១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ណាសស៊ីម អឺភែរឺល (ខេ អេច) ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី២០.១២ .២០១១

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន ណាសស៊ីម អឺភែរឺល (ខេ អេច) ភីធីអ៊ី អិលធីឌី (NASSIM APPAREL (KH) PTE., LTD.) តំណាងដោយ លោក EDWARD ANG BOON CHEOW សញ្ជាតិសឹង្ហបុរី អាយុ៥៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E1233765C ចុះថ្ងៃទី០៨.០៥.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ 17B Leedon Park, Singapore 267895 ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ស្តង់ដារអន្តរជាតិ ISIC Rev.4 Code
សម្លៀកបំពាក់ (កាត់ដេរ និងប៉ាក់)	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រកាត់ដេរ និងប៉ាក់សម្លៀកបំពាក់ ណាសស៊ីម អ៊ីតែរីល (ខេ អេច) ភីធីអ៊ី អិលធីឌី "*

ទីតាំងរោងចក្រ ៖ *" ផ្លូវជាតិលេខ៣ ភូមិក្របីគ្រាំ និងភូមិព្រៃរោង ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

១ ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៤០៧ ឧ.ស.ថ.ក.ក ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ៦៨៥/១២ គ.វ.ក ចុះថ្ងៃទី៣០.០៣.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ដុងឌូ ថេកស្ទាយ (ខេមបូឌា) ចុះថ្ងៃទី២៣.០៣.២០១២

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុនដុងឌូ ថេកស្ទាយ (ខេមបូឌា)(DONGDU TEXTILE (CAMBODIA) CO.,LTD.)តំណាងដោយ លោក HUANG YONGSHENG សញ្ជាតិចិន អាយុ៥៥ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G54780554 ចុះថ្ងៃទី០១.០៨.២០១១ មានអាសយដ្ឋានបច្ចុប្បន្ន ៖ ZHANGJIAGANG ECONOMIC DEVELOPMENT ZONE (No.638, JIN'GANG AVENUE, YANGSHE TOWN). ជាម្ចាស់ក្រុមហ៊ុនធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code**
សម្លៀកបំពាក់	១៤១០

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ដុងខួ ថេកស្តាយ (ខេមបូឌា) "*
ទីតាំងរោងចក្រ ៖ *" អាគារ១៦-១៧ (សួនឧស្សាហកម្មវឌ្ឍនៈII) ផ្លូវជាតិលេខ៣ សង្កាត់ក្រាំងពង្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ៤០៨ ឧរម.ក.ឧ.ពក

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-បានឃើញលិខិតលេខ១៩៣/១២ គ.វ.ក ចុះថ្ងៃទី០១.០២.២០១២ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុនគ្រីស្តាល់ រាយស៍ (កម្ពុជា) ចុះថ្ងៃទី២៦.០១.២០១២

សម្រេច

ប្រការ១: អនុញ្ញាតឲ្យក្រុមហ៊ុន គ្រីស្តាល់ រាយស៍(កម្ពុជា)(CRYSTAL RICE (KAMPUCHEA) Co.,LTD.) តំណាងដោយ លោកស្រី កែវ ម៉ាលី សញ្ជាតិខ្មែរ អាយុ៥៧ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ០១០៣៨៣៩៦២ ចុះថ្ងៃទី០៦.០៤.២០០២ មានអាសយដ្ឋានបច្ចុប្បន្នៈ ផ្ទះលេខ១០៥បេ ភូមិតាដៅ សង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ. ជាម្ចាស់រោង ចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាផលិតកម្ម៖

ឈ្មោះផលិតផល	លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code
អង្ករ	១០៦១

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១ , ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone : 855-23-211141 , Fax : 855-23-428263

ផ្លាកឈ្មោះរោងចក្រ ៖ *" រោងចក្រកិនស្រូវ គ្រីស្តាល់ រាយស៍ (កម្ពុជា)"*

ទីតាំងរោងចក្រ ៖ *"ភូមិព្រៃកគ្រែង ឃុំព្រៃកត្នោត ស្រុកទឹកឈូ ខេត្តកំពត "*

ប្រការ២: -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ៣: -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិនិងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានាស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ៤: ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

ប្រការ៥: ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

ប្រការ៦: ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

ប្រការ៧: -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

ប្រការ៨: -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

ប្រការ៩: -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

ប្រការ១០: រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

ប្រការ១១: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

ប្រការ១២: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១៣: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

ប្រការ១៤: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពត និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១៥: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ស៊ុយ_សែម

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលាខេត្តកំពត
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ៥០៥ ឧរម.កឧ-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១២

ប្រកាសបង្កើតរោងចក្រ

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

